

#everydayheroes #ThinkFamilies #weareChildSafe #ngo #recruitment #job #opportunity #SiemReap #education #teaching #peopledevelopment #khmerspeaker #socialwork #childprotection

## គ្រូបង្រៀនកម្រិតបឋមសិក្សា

friends cambodia
កល្យាណមិត្ត
kaliyan mith

### សួស្តីអ្នកទាំងអស់គ្នា ពីកម្មវិធីកល្យាណមិត្ត ខេត្តសៀមរាប!

តើអ្នកចាប់អារម្មណ៍ក្នុងការផ្តល់ការអប់រំប្រកបដោយគុណភាពល្អបំផុតសម្រាប់កុមារតូចៗដែរឬទេ? តើអ្នកចង់ក្លាយជាផ្នែកមួយនៃក្រុមការងារដ៏សកម្មដែលធ្វើការជាមួយដៃគូនានានៅក្នុងខេត្តសៀមរាប និងទូទាំងប្រទេសកម្ពុជាដែរឬទេ?

ប្រសិនបើអ្នកឆ្លើយថា "បាទ ឬ ចាស" នោះអ្នកប្រហែលជាមនុស្សដែលយើងត្រូវការហើយ

ខាងក្រោមនេះជាការពណ៌នាអំពីអ្វីដែលអ្នកគួរមាន?

• អ្នកគឺជាមនុស្សដែលប្រកបដោយឯករាជ្យភាព និងភាពរហ័សរហួន ស្រលាញ់ការងារសង្គម ដែលអាចធ្វើការសហការយ៉ាងជិតស្និទ្ធជាមួយក្រុមអប់រំ ក្រុមផ្សេងទៀត និងអង្គការដៃគូផ្សេងៗ
• អ្នកមានការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការការពារកុមារពីការរំលោភបំពានផ្សេងៗ និងផ្តល់សេវាគាំទ្រប្រកបដោយគុណភាពដល់ពួកគេ
• អ្នកមានការទំនាក់ទំនងល្អជាមួយកុមារ ហើយអ្នកធ្វើជាគំរូដ៏ល្អសម្រាប់ពួកគេផងដែរ
• អ្នកមានការប្តេជ្ញាចិត្តយ៉ាងមុតមាំចំពោះគុណភាព និងលទ្ធផលវិជ្ជមានសម្រាប់ក្រុមគោលដៅ ដែលត្រូវការការគាំទ្រ
• អ្នកមានចំណាប់អារម្មណ៍ខ្លាំងនៅក្នុងការងារសង្គម និងធ្វើការជាមួយ កុមារ យុវវ័យ និងក្រុមគ្រួសាររបស់ពួកគេ
• អ្នកជាមនុស្សបើកចំហ និងរីករាយក្នុងការរៀនសូត្រ និងការសម្របខ្លួនទៅនឹងស្ថានភាពថ្មី
• អ្នកគឺជាមនុស្សដែលមានការរួសរាយរាក់ទាក់ និងជាមនុស្សដែលចូលចិត្តការប្រាស្រ័យទាក់ទង ជាមួយមនុស្សជាច្រើននៅជុំវិញខ្លួន
• អ្វីដែលអ្នកគួរមានបន្ថែមគឺអាចនិយាយភាសាអង់គ្លេសបាន ចេះប្រើប្រាស់កុំព្យូទ័រ និងមាន វិញ្ញាបនបត្រគរុកោសល្យកាន់តែប្រសើរ

អង្គការហ្រ្វេនស៍ មានក្រុមការងារដែលមានភាពរហ័សរហួនជាច្រើនដែលកំពុងផ្តល់សេវាកម្មប្រកប ដោយភាពច្នៃប្រឌិតឱ្យទៅ កុមារ យុវវ័យ ក្រុមគ្រួសារ និងសហគមន៍របស់ពួកគេ។ អ្នកទាំងអស់គ្នា រួមទាំងដៃគូរបស់យើងកំពុងបង្កើតប្រព័ន្ធមួយដែលនឹងផ្តល់ការការពារដល់អ្នកដែលត្រូវការជំនួយ និងការគាំទ្រ ដើម្បីប្រែក្លាយពួកគេទៅជាពលរដ្ឋដែលមានផលិតភាពសម្រាប់ប្រទេសជាតិរបស់ ពួកគេ។

តាមរយៈការធ្វើដូចនេះ យើងកំពុងបង្កើតវេទិកាគ្មានដែនកំណត់សម្រាប់ក្រុម និងដៃគូរបស់យើង ដើម្បីរៀនពីការងាររបស់ពួកគេ និងរៀនពីគ្នាទៅវិញទៅមក ដើម្បីបង្កើតឱកាសសិក្សានៅគ្រប់ទីកន្លែង! យើងកំពុងស្វែងរកសមាជិកក្រុមថ្មីបន្ថែម ដើម្បីផ្តល់ការបង្រៀនដល់កុមារតូចៗកម្រិត បឋមសិក្សាប្រកបដោយគុណភាពក្នុងខេត្តសៀមរាប ដូច្នេះពួកគេអាចកសាងអនាគតរបស់ពួកគេ។ អ្នកនឹងត្រូវផ្តល់ថ្នាក់បំប៉ន និងថ្នាក់ពន្លឿនដល់កុមារដែលមិនធ្លាប់បានចូលរៀន ឬដែលបានបោះបង់ការសិក្សា ដើម្បីមានសមត្ថភាពចូលទៅរៀននៅសាលារដ្ឋ។ តាមរយៈការធ្វើដូច្នេះ ទើបអ្នកអាចបញ្ជូនពួកគេទៅក្នុងប្រព័ន្ធសាលារដ្ឋ ហើយបន្តនៅក្នុងសាលារហូតដល់បញ្ចប់ការសិក្សា។ អ្នកនឹងមានឱកាសប្រើប្រាស់គំនិតច្នៃប្រឌិតរបស់អ្នក ខណៈពេលដែលអ្នកបង្រៀនកុមារនៅក្នុងមណ្ឌលអប់រំរបស់យើង ហើយមណ្ឌលអប់រំរបស់យើងក៏មាននៅក្នុងសហគមន៍ផងដែរ។

អ្នកនឹងធ្វើការជាមួយនឹងក្រុមពហុជំនាញដែលមានជាង ៣០០ #EverydayHeroes ដែលមាននៅក្នុងប្រទេសកម្ពុជា ថៃ ឡាវ ឥណ្ឌូនេស៊ី និងមីយ៉ាន់ម៉ា!

ទាំងអស់គ្នា យើងនឹងផ្តល់សេវាកម្មដល់កុមារ យុវវ័យ គ្រួសារ និងសហគមន៍ នៅក្នុងគម្រោងមួយ ចំនួនលើប្រធានបទដូចជា ការការពារកុមារ ការអប់រំ ការធ្វើសមាហរណកម្មគ្រួសារ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងរកការងារ ដូច្នេះពួកគេអាចកសាងអនាគតរបស់ពួកគេបាន!

## ព័ត៌មានបន្ថែមអំពីការដាក់ពាក្យ

បើមានចំណាប់អារម្មណ៍ សូមផ្ញើប្រវត្តិរូបសង្ខេបរបស់អ្នកមកឥឡូវនេះតាមរយៈអ៊ីមែល៖

*hr.kaliyanmith@friends-international.org*

បេក្ខជន ឬបេក្ខនារីទាំងអស់នឹងឆ្លងកាត់ការត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់ទៅលើគោលការណ៍ការការពារកុមារ និងកិច្ចការពារប្រឆាំងនឹងការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ *Beneficiary Protection Policy and PSEA Policy.*

Friends team